ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ៤២២៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៦

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការអនុវត្តការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក

ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ អនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើមុខទំនិញមួយចំនួន សេចក្ដីជូនដំណឹងលេខ ០១៥ សហវ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក និងសេចក្ដីជូនដំណឹងលេខ ០០៥ សហវ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់សហគ្រាសផលិតផលិតផលជាប់អាករពិសេសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ តទៅ អត្រាអាករពិសេសលើមុខទំនិញដែលផលិតនិងផ្គត់ផ្គង់ក្នុងស្រុកត្រូវបានកែសម្រួល និងកំណត់ដូចខាងក្រោម÷

១) ៣០ ភាគរយ លើមុខទំនិញស្រាបៀរគ្រប់ប្រភេទ

២) ៣៥ ភាគរយ លើមុខទំនិញសុរា (ស្រា) គ្រប់ប្រភេទ

៣) ២០ ភាគរយ លើមុខទំនិញបារីគ្រប់ប្រភេទ។

ដោយឡែក មូលដ្ឋានគិតអាករពិសេសត្រូវអនុវត្តដដែល តាមសេចក្ដីជូនដំណឹងលេខ ០១៥ សហវ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក និងសេចក្ដីជូនដំណឹងលេខ ០០៥ សហវ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជានាយក បណ្ណាធិការ និងម្ចាស់សហគ្រាសផលិតផលិតផលជាប់អាករពិសេស ទាំងអស់មេត្តាជ្រាប និងអនុវត្តឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

Collection by VCAT Professional Consultant